## ទិដ្ឋាការចេញចូលច្រើនដងក្នុងនាមជាអ្នកវប្បធម៌ ឬបញ្ញវន្ត

សាមីជនមានសញ្ជាតិខ្មែរ និងសាមីជនមានសញ្ជាតិនៃបណ្តាប្រទេសអាស៊ីប៉ាស៊ីហ្វិក (សម្រាប់សញ្ជាតិចិន ហ្វីលីពីន វៀតណាមមាននីតិវិធីខុសពីនេះ) អាចដាក់ពាក្យស្នើសុំទិដ្ឋាការប្រភេទនេះបាន។(សូមចូលមើលសម្រាប់ប្រទេសដែលអាចស្នើសុំបាន)
ទិដ្ឋាការប្រភេទនេះមានសុពលភាពអតិបរមា៣ឆ្នាំ(ករណីខ្លះទទួលបាន១ឆ្នាំ) និងអាចស្នាក់នៅម្តងរយៈពេល៩០ថ្ងៃ។

**★★★ អ្នកដែលអាចដាក់ពាក្យបាន ★★★**

បុគ្គល ឬប្តីប្រពន្ធ/កូនរបស់អ្នកស្ថិតក្រោមលក្ខខណ្ឌមួយក្នុងចំណោមខាងក្រោម៖

១. ជាសិល្បៈករល់ដាប់អន្តរជាតិ (សិល្បៈករដែលមានស្នាដៃ តន្ត្រី របាំ និងអក្សរសាស្ត្រ។ល។)

២. ជាអ្នកឯកទេសផ្នែកមនុស្សសាស្ត្រ (អក្សរសាស្ត្រ ច្បាប់ សេដ្ឋកិច្ច។ល។) ឬអ្នកវិទ្យាសាស្ត្រ (បច្ចេកវិទ្យា វេជ្ជសាស្ត្រ។ល។)

៣. ជាអត្តពលិកស្ម័គ្រចិត្តដែលមានស្នាដៃត្រូវបានទទួលស្គាល់

៤. ជាសាស្ត្រាចារ្យ, ជំនួយការសាស្ត្រចារ្យ នៃសាកលវិទ្យាល័យ ឬមហាវិទ្យាល័យ (ពេញម៉ោងតែប៉ុណ្ណោះ)

៥. ជានាយក (ឬដំណែងលើនេះ) នៃវិទ្យាស្ថានជាតិស្រាវជ្រាវ ឬវិទ្យាស្ថានស្រាវជ្រាវសាធារណៈ ឬសារមន្ទីរជាតិ

| | ឯកសារតម្រូវ | | កំណត់ចំណាំ |
|---|---|---|---|
| ១ | ☐ | លិខិតឆ្លងដែន ច្បាប់ដើម | ･មិនមានស្នាមប្រឡាក់ ឬការខូចខាត<br>･ត្រូវមាន២ទំព័រសម្រាប់បិទទិដ្ឋាការ |
| ២ | ☐ | ពាក្យស្នើសុំទិដ្ឋាការ *ច្បាប់ដើម*<br>*(បិទរូបថត១សន្លឹក)*<br><br>សេចក្តីពន្យល់អំពីការបំពេញពាក្យស្នើសុំ (ខ្មែរ) | ･រូបថតបិទកាត (ថតថ្មីក្នុងរយៈពេល៦ខែ)<br>(បណ្តោយ: ៤.៥សង់ទីម៉ែត្រ x ទទឹង: ៣.៥សង់ទីម៉ែត្រ, ផ្ទៃពណ៌ស, រូបថតពណ៌ ឬសខ្មៅ)<br>･បំពេញពាក្យ "N/A" សម្រាប់សំណួរដែលមិនត្រូវនឹងលក្ខខណ្ឌរបស់អ្នក |
| ៣ | ☐ | លិខិតបញ្ជាក់ការងារ | ･បញ្ជាក់៖ មុខតំណែង រយៈពេលនៃការងារ ប្រាក់បៀវត្សរ៍ ។ល។ (មិនមានកំណត់ទម្រង់) |

| | | | |
|---|---|---|---|
| ៤ | □ | ឯកសារបញ្ជាក់(១)ដល់(៥) | ★★★ អ្នកដែលអាចដាក់ពាក្យបាន ★★★ |
| ៥ | □ | លិខិតស្នើសុំទិដ្ឋាការចេញចូលច្រើនដង | · សរសេរពីមូលហេតុនៃការស្នើសុំទិដ្ឋាការចេញចូលច្រើនដង។ (មិនមានកំណត់ទម្រង់) |
| ៦ | □ | ឯកសារបញ្ជាក់ពីទំនាក់ទំនង | · សម្រាប់ករណីប្តីប្រពន្ធ/កូនដាក់ពាក្យស្នើសុំទិដ្ឋាការចេញចូលច្រើនដងក្នុងពេលជាមួយគ្នា។ (សូមសរសេរបញ្ចូលទាំងមូលហេតុក្នុងលិខិតស្នើសុំទិដ្ឋាការចេញចូលច្រើនដងខងលើ) |